00681367

E83

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 03 / 05 / 2011
ម៉ោង (Time/Heure): 10:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការបន្ទាញរបស់អៀង សារី លើផ្នែកនៃសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលតម្រូវឲ្យមានសារណាបន្ថែមទាក់ទងនឹងការអនុវត្តនៅ អវតក នូវឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវអន្តរជាតិ**

---

| <u>ដាក់ដោយ៖</u> | <u>ផ្ញើជូន៖</u> | <u>ផ្ញើជូន៖</u> |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្ដីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | **ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់** |
| | ចៅក្រមបំរុង យូរ ឧត្ដារ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះសូមកំណត់ផ្នែកនៃសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ("សាលដីការបស់ អបជ")[1] ដែលតម្រូវសារណាបន្ថែមទាក់ទងនឹងការអនុវត្តនៅ អវតក នៃឧក្រិដ្ឋកម្មអន្តរជាតិ និង ទម្រង់នៃការទទួលខុសត្រូវ អនុលោមតាមសំណើរបស់អង្គបុរេជំនុំជម្រះ[2] ។ សារណាគ្រាន់តែបង្ហាញដល់អង្គបុរេជំនុំជម្រះ ក្នុងករណីដែលសារណាបន្ថែមទៀតត្រូវបានតម្រូវដើម្បីបន្ថែមលើការបង្ហាញជាបឋមរបស់លោក អៀង សារី ពាក់ព័ន្ធនឹងអញ្ញត្រកម្ម[3] ។

## I សំណើលើសារណាបន្ថែម

### ក. គោលការណ៍នីត្យានុកូលភាព

#### i. ថាតើគោលការណ៍នីត្យានុកូលភាពជាតិ ឬគោលការណ៍នីត្យានុកូលភាពអន្តរជាតិ អនុវត្តនៅ អវតក ដែរ ឬអត់

១. មេធាវីការពារក្តីស្នើឱ្យពិចារណាថា កំហុសជាមូលដ្ឋាននៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងគោលការណ៍នីត្យានុកូលភាព គឺការកំណត់ដោយភ័ន្តច្រឡំរបស់អង្គបុរេជំនុំជម្រះដែល

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ D427/1/30 ។

[2] សេចក្តីណែនាំដល់ភាគីទាក់ទងនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ E51/7 នៅកថាខណ្ឌទី២ ។ អង្គបុរេជំនុំជម្រះស្នើឱ្យមេធាវីការពារក្តី "កំណត់នៅក្នុងសារណាមិនឱ្យលើសពី ៥ ទំព័រ...នូវផ្នែកនៃសាលដីការបស់អង្គបុរេជំនុំជម្រះ ដែលសារណាបន្ថែមនោះលើកឡើង ។ អង្គបុរេជំនុំជម្រះលើកឡើងថា "អង្គបុរេជំនុំជម្រះនឹងចេញសេចក្តីណែនាំបន្ថែមទាក់ទងនឹងសារណាទាំងនោះ នៅក្នុងពេលវេលាសមស្រប ។ ភាគីនឹងមានឧកាសលើកឡើងនូវទឡ្ហីករណ៍ផ្ទាល់មាត់នៅសវនាការបឋម" ។

[3] សូមមើលការសង្ខេបអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ និងការជូនដំណឹងពីគោលបំណងនៃមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការដែលចេញនៅថ្ងៃអនាគត ជំនួសឱ្យការសម្រេចមានសំអាងហេតុ ដែលបើកផ្លូវប្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ E51/4 ។ សូមកត់សម្គាល់ថាញត្តិនេះ<u>មិនមែន</u>ជាសារណាបន្ថែមទេ ។ មេធាវីការពារក្តីនឹងមិនលើកឡើងនូវរាល់កំហុសទាំងអស់ ដែលខ្លួនយល់ឃើញថាអង្គបុរេជំនុំជម្រះបានប្រព្រឹត្ត ប៉ុន្តែ មេធាវីការពារក្តីស្នើដាក់កំហិតសារណាបន្ថែមរបស់ខ្លួនដែលនឹងធ្វើពេលខាងមុខ ទៅលើកំហុសទាំងអស់នេះ បើសិនជាគេអាចយកធ្វើជាសំអាង ដែលអាចបណ្តាលឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចដោយមិនត្រឹមត្រូវលើបញ្ហា ថាតើឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវអន្តរជាតិ អាចអនុវត្តនៅ អវតក បានដែរ ឬអត់ និង ថាតើបទល្មើស និងទម្រង់នៃការទទួលខុសត្រូវទាំងនេះ ត្រូវយកមកអនុវត្តយ៉ាងម្តេច។

ថាគោលការណ៍នីត្យានុកូលភាពដែលមានចែងនៅក្នុងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") អាចអនុវត្តបាន ជាជាងចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ អង្គបុរេជំនុំជម្រះកំណត់ថា "ដោយសារយោងយ៉ាងច្បាស់ទៅលើមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចំពោះករណីឧក្រិដ្ឋកម្មអន្តរជាតិ គឺគ្មានអ្វីគួរឲ្យសង្ស័យនោះឡើយ ដែលថាគោលការណ៍នីត្យានុកូលភាពដែលមានចែងក្នុងច្បាប់ អវតក គឺជាគោលការណ៍នីត្យានុកូលភាពអន្តរជាតិដែលធ្វើឲ្យមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដែលមានលក្ខណៈជាបទឧក្រិដ្ឋជាតិ ឬអន្តរជាតិ"[4] ។ សារណាបន្ថែមគឺចាំបាច់ ដើម្បីពន្យល់ថាហេតុអ្វីបានជាគោលការណ៍នីត្យានុកូលភាពដែលត្រូវតែអនុវត្តដោយ អវតក ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងអស់ និងទម្រង់នៃការទទួលខុសត្រូវ គឺជាគោលការណ៍នីត្យានុកូលភាពមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងដើម្បីពន្យល់ថាការយោងរបស់ច្បាប់បង្កើត អវតក ទៅលើមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនធ្វើឲ្យផ្លាស់ប្តូរចំណុចនេះទេ ។

**ii. ថាតើ អវតក ជាតុលាការជាតិ ឬ តុលាការអន្តរជាតិ ឬ ក៏ជាតុលាការដែលមាន "លក្ខណៈជាអន្តរជាតិ"**

២. ការកំណត់ដោយភ័ន្តច្រឡំរបស់អង្គបុរេជំនុំជម្រះដែលថា ច្បាប់បង្កើត អវតក ចែងពីការអនុវត្តគោលការណ៍នីត្យានុកូលភាពអន្តរជាតិ នាំឲ្យអង្គបុរេជំនុំជម្រះធ្វើសេចក្តីសន្និដ្ឋានដោយភ័ន្តច្រឡំថាអង្គបុរេជំនុំជម្រះមិនចាំបាច់ធ្វើការកំណត់ថា តើ អវតក ជាតុលាការអន្តរជាតិ ឬជាតុលាការជាតិនោះទេ ។ អង្គបុរេជំនុំជម្រះយល់ឃើញ "លក្ខណៈរបស់ អវតក ជាតុលាការ មិនបានបង្កើតផលវិបាកអ្វីចំពោះយុត្តាធិការរបស់ អវតក ក្នុងការជំនុំជម្រះឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដូចមានចែងក្នុងច្បាប់ អវតក..."[5] ។ បើទោះជាយ៉ាងនេះក៏ដោយ ក៏អង្គបុរេជំនុំជម្រះបន្តលើកឡើងថា អវតក ជាតុលាការមានលក្ខណៈជាអន្តរជាតិ"[6] ។ គេចាំបាច់កំណត់ថា តើ អវតក ជាតុលាការជាតិ ឬ តុលាការអន្តរជាតិ ពិព្រោះគោលការណ៍នីត្យានុកូលភាពត្រូវតែកំណត់ដោយការ

[4] សាលដីការបស់ អបជ នៅកថាខណ្ឌទី២១៣ ។

[5] ដូចខាងលើ នៅកថាខណ្ឌទី ២១២ ។

[6] ដូចខាងលើ នៅកថាខណ្ឌទី ២១៥ ។

00681370



យោងថា តើ អវតក ជាតុលាការជាតិ ឬ តុលាការអន្តរជាតិ (ហើយប្រសិនបើវាជាតុលាការជាតិវិញ ថាតើ អវតក អាចអនុវត្តច្បាប់អន្តរជាតិដោយផ្ទាល់ដែរ ឬអត់) ដោយសារច្បាប់បង្កើត អវតក មិនបានផ្លាស់ប្តូរគោលការណ៍នីត្យានុកូលភាពដែលអាចអនុវត្តបាន ។ ការកំណត់ថា អវតក គឺជា "តុលាការដែលមានលក្ខណៈអន្តរជាតិ" ក៏បញ្ជាក់ន័យសម្រាប់អញ្ញត្រកម្មមួយទៀតដែលមេធាវីការពារក្តីបានលើកឡើង[7] ដែលបានបង្ហាញបន្ថែមទៀតថាសារណាបន្ថែម គឺចាំបាច់ ។ សារណាបន្ថែមគឺចាំចាច់ ដើម្បីពន្យល់ឲ្យបានពិស្តារថា ហេតុអ្វីបានជាភាពខុសគ្នានេះគឺពាក់ព័ន្ធ និងត្រូវបានកំណត់ និងដើម្បីពន្យល់បន្ថែមទៀតថា ការកំណត់របស់អង្គបុរេជំនុំជម្រះដែលថា អវតក គឺជា "តុលាការដែលមានលក្ខណៈអន្តរជាតិ"[8] គឺនៅតែមិនច្បាស់លាស់ និងមិនមានប្រយោជន៍ដល់ការវិភាគនេះ ។

**iii. ថាតើការវាយតម្លៃចំពោះភាពអាចព្យាករណ៍បាន និងការដឹងជាមុនថាបទល្មើសមានច្បាប់ចែង តម្រូវថាឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ មានចែងនៅក្នុងច្បាប់ជាតិដែលនៅជាធរមាន**

៣. ការកំណត់ដោយភ័ន្តច្រឡំរបស់អង្គបុរេជំនុំជម្រះដែលថាច្បាប់បង្កើត អវតក មានចែងពីការអនុវត្តនៃគោលការណ៍នីត្យានុកូលភាពអន្តរជាតិ នាំឲ្យអង្គបុរេជំនុំជម្រះធ្វើការសន្និដ្ឋានដោយភ័ន្តច្រឡំថា "ដើម្បីឲ្យបទដ្ឋាននៃគោលការណ៍នីត្យានុកូលភាពបំពេញបាននៅ អវតក លក្ខខណ្ឌតម្រូវការនេះនៃអត្ថិភាពនៃឧក្រិដ្ឋកម្មនៅក្នុងច្បាប់ជាតិ មិនមែនជាអាជ្ញាបញ្ហានោះឡើយ តែលក្ខខណ្ឌតម្រូវនេះមានលក្ខណៈជាលក្ខខណ្ឌដែលមានក៏បាន និងគ្មានក៏ដោយ ។ គ្រាន់តែរកឃើញថាមានឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវនោះ ពិតជាមានអត្ថិភាពនៅក្នុង [ច្បាប់ជាតិ ច្បាប់អន្តរជាតិ ឬគោលការណ៍ទូទៅនៃច្បាប់ ដែលបានទទួលស្គាល់ដោយសហគមន៍ជាតិ នៅពេលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត][9]។ សារណាបន្ថែមគឺចាំបាច់ ដើម្បីពន្យល់ថា ហេតុអ្វីបានការវាយតម្លៃពីភាពអាចព្យាករណ៍បាននិងការអាចដឹងថាបទល្មើសមានច្បាប់ចែង តម្រូវថាឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ត្រូវមានអត្ថិភាពនៅក្នុងច្បាប់នៅជាធរមាននៅពេលបទឧក្រិដ្ឋកើតឡើង ។

---

[7] សូមមើល ដូចដើងទំព័រខាងលើ កថាខណ្ឌទី១៣១ ។

[8] ដូចខាងលើ នៅកថាខណ្ឌទី ២១៥-២២២ ។

[9] ដូចខាងលើ នៅកថាខណ្ឌទី ២៣៨ ។

៤. អង្គបុរេជំនុំជម្រះក៏យល់ឃើញថា នៅដំណាក់កាលនេះនៃដំណើរការនីតិវិធីអង្គបុរេជំនុំជម្រះចាំបាច់តែកំណត់ថា តើឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវឆ្លងផុតពីការវាយតម្លៃសត្យានុម័ត ដែរ ឬ អត់[10] ។ សារណាបន្ថែមគឺចំបាច់ ដើម្បីពន្យល់ហេតុអ្វីបានជាអង្គជំនុំជម្រះសាលាដំបូងអនុវត្តការវាយតម្លៃសត្យានុម័ត និងថាហេតុអ្វីបានជាភាពអាចព្យាករណ៍បាន និងការដឹងថាមានច្បាប់ចែងអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គួរតែ ឬ ត្រូវតែបានកំណត់នៅមុនសវនាការ ។

**iv. ថាតើអង្គបុរេជំនុំជម្រះលើកមកសំអាងដោយមិនត្រូវនូវកាតព្វកិច្ចរបស់រដ្ឋ ដែរ ឬអត់**

៥. នៅផ្នែកមួយចំនួននៃសាលាដីកា អង្គបុរេជំនុំជម្រះបានយោងទៅលើកាតព្វកិច្ចនានាដែលប្រទេសកម្ពុជាមានក្នុងខណៈជារដ្ឋមួយ ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌជាបុគ្គល[11] ។ សារណាបន្ថែមគឺចាំបាច់ ដើម្បីពន្យល់ថាកាតព្វកិច្ចរបស់រដ្ឋមួយ ត្រូវតែញែកឲ្យដាក់ចេញពីកាតព្វកិច្ចរបស់បុគ្គលម្នាក់ ហើយបន្ថែមពីលើនេះកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋមួយ ត្រូវតែខុសគ្នាពីអ្វីដែលរដ្ឋធ្វើនៅក្នុងស្រុក ។

**ខ. អាជ្ញាយុកាលនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ**

៦. អង្គបុរេជំនុំជម្រះបានបដិសេធចោលនូវការលើកឡើងរបស់មេធាវីការពារក្តីថា អាជ្ញាយុកាលរារាំងការអនុវត្តនៅ អវតក នៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ពីព្រោះ "អនុសញ្ញាទីក្រុងហ្សឺណែវជាច្បាប់អាចអនុវត្តបានតាមមាត្រា ៦ នៃច្បាប់បង្កើត អវតក ចែងថាឧក្រិដ្ឋកម្មសង្គ្រាមពុំមានអាជ្ញាយុកាលនោះទេ ដែលបង្ហាញថាពុំមានអាជ្ញាយុកាលដែលអាចអនុវត្តបានទេ"[12] ។ មាត្រា ៦ នៃច្បាប់បង្កើត អវតក ចែងថា អង្គជំនុំជម្រះវិសាមញ្ញ "មានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្ត ឬបានបញ្ជាឲ្យប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩..."។ មាត្រា ៦ ធ្វើឲ្យទៅជាបទល្មើសនៃការបំពារបំពានដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ។ អនុសញ្ញានេះ*មិនបាន*ចែងអំពីការអនុវត្តដោយផ្ទាល់នៃបទប្បញ្ញត្តិទាំងអស់នៃអនុសញ្ញាទីក្រុងហ្សឺណែវទេ ។ សារណាបន្ថែមគឺចាំបាច់ ដើម្បីពន្យល់ពីការភ័ន្តច្រឡំនៅក្នុងការវិភាគរបស់អង្គបុរេជំនុំជម្រះ ។

---

[10] ដូចខាងលើ នៅកថាខណ្ឌទី ២១០, ២៣៧ ។

[11] សូមមើល ជាឧទាហរណ៍ដូចជើងទំព័រខាងលើ កថាខណ្ឌទី ២៤៤-២៤៥, ២៥៦-២៥៧ ។

[12] ដូចខាងលើ នៅកថាខណ្ឌទី ៧៣ ។

### គ. ការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

#### i. ថាតើការប្តឹងជំទាស់នឹងវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចទទួលយកបានថា ជាការប្តឹងជំទាស់នឹងយុត្តាធិការដែរ ឬអត់

៧. អង្គបុរេជំនុំជម្រះយល់ឃើញថាខ្លួនគ្មានយុត្តាធិការ ដើម្បីពិចារណាថាតើ កសចស ពិតជាត្រឹមត្រូវដែរ ឬអត់ ក្នុងការមិនរាប់បញ្ចូលអត្ថិភាពនៃគោលនយោបាយចាត់តាំងថា ជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយផ្អែកលើមូលដ្ឋានថា "ទឡ្ហីករណ៍របស់សហមេធាវី" គឺពាក់ព័ន្ធទៅនឹងរូបរាងនៃធាតុផ្សំនៃបទល្មើស ហើយដូច្នេះ មិនតំណាងឲ្យការប្តឹងទៅនឹងយុត្តាធិការទេ"[13] ។ សារណាបន្ថែមគឺចាំបាច់ ពីព្រោះបើសិនអង្គជំនុំជម្រះសាលាដំបូងទទួលយកការកំណត់ដោយភ័ត្តច្រឡំរបស់អង្គបុរេជំនុំជម្រះថាការប្តឹងជំទាស់នេះ គឺមិនមែនជាបណ្តឹងជំទាស់នឹងយុត្តាធិការ នោះវាអាចធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធបញ្ហានេះថា ជាអញ្ញត្រកម្មវិញ[14] ។

#### ii. ថាតើការជំទាស់ទៅនឹងចំណាត់ថ្នាក់មិនត្រឹមត្រូវ នៃ"ការជម្លៀសប្រជាជនដោយបង្ខំ" គឺជាការជំទាស់នឹងយុត្តាធិការដែរឬទេ

៨. អង្គបុរេជំនុំជម្រះ បានលើកឡើងថាការជំទាស់ទៅនឹង "ចំណាត់ថ្នាក់មិនត្រឹមត្រូវ" នៃការជម្លៀសប្រជាជនដោយបង្ខំថាជាធាតុផ្សំនៃបទល្មើសមួយ ឬមួយទៀត...ដែលជាទឡ្ហីករណ៍នៃការអនុវត្តការអះអាងតែប៉ុណ្ណោះ ដូច្នេះហើយមិនតំណាងឲ្យការប្តឹងជំទាស់ផ្នែកយុត្តាធិការដែលអាចទទួលយកបានឡើយ[15]"។ ការសម្រេចដែលមានកំហុងឆ្គងដោយអង្គបុរេជំនុំជម្រះដែលថាការជំទាស់ទៅនឹងចំណាត់ថ្នាក់មិនត្រឹមត្រូវនៃការជម្លៀសប្រជាជនដោយបង្ខំ មិនមែនជាបញ្ហាយុត្តាធិការ នោះវា *អាច*នាំឲ្យអង្គជំនុំសាលាដំបូង យល់ឃើញថា បញ្ហានេះមិនមែនជាអញ្ញាត្រកម្មសមស្រប[16]។ សារណាបន្ថែម គឺចាំបាច់ដើម្បីពន្យល់ថាតើហេតុអ្វីបានជាការលើកឡើងបែបនេះ មិនត្រឹមតែមានកំហុសឆ្គងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនស្របទៅនឹងគោលជំហររបស់អង្គបុរេជំនុំជម្រះខ្លួនឯង

---

[13] ដូចខាងលើ នៅកថាខណ្ឌទី ៨៣(៤) និងកថាខណ្ឌទី ៨៦ ។

[14] មេធាវីការពារក្តីបានដាក់បញ្ហាអញ្ញត្រកម្មទាំងនេះតាមវិធាន ៨៩(ក) (យុត្តាធិការរបស់អង្គជំនុំជម្រះ) ។

[15] សាលដីការបស់ អបជ នៅកថាខណ្ឌទី៩១។

[16] មេធាវីការពារក្តីបានដាក់អញ្ញាត្រកម្មទាំងនេះស្របតាមវិធាន (៨៩) (ក) (យុត្តាធិការរបស់អង្គជំនុំជម្រះ)។

00681373



ទៀតផង[17]។

**iii. ថាតើការធ្វើទារុណកម្ម គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬទេ**

៩. អង្គបុរេជំនុំជម្រះយល់ស្របថា "សេចក្តីប្រកាសស្តីពីការធ្វើទារុណកម្មបានចងក្រងច្បាប់ទំនៀមទម្លាប់មុនគេ និងយល់ឃើញថាត្រឹមពីឆ្នាំ១៩៧៥ ដល់១៩៧៩ ...ទង្វើបែបនេះត្រូវបានចាត់ទុកជាបទល្មើសក្នុងន័យដែលមានការយល់ដឹងជាទូទៅ និងដែលអាចប្រមើលមើលបានចាប់ពីពេលនោះមក[18]"។ សារណាបន្ថែម គឺចាំបាច់ដើម្បីបង្ហាញថាតើ សេចក្តីប្រកាសស្តីពីការធ្វើទារុណកម្មមិនអាចត្រូវបានគេលើកយកមកសំអាងជាភស្តុតាងនៃការធ្វើទារុណកម្ម ជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ១៩៧៥ ដល់១៩៧៩ បានឡើយ។

**iv. ថាតើគោលការណ៍នីត្យានុកូលភាពភ្ជាប់ទៅនឹងប្រភេទទាំងមូលនៃអំពើអមនុស្សធម៌ដទៃទៀត ប៉ុន្តែមិនភ្ជាប់ទៅនឹងប្រភេទរងនីមួយៗទេ ឬយ៉ាងណា**

១០. អង្គបុរេជំនុំជម្រះយល់ឃើញថា "លក្ខណ្ឌតម្រូវនៃគោលការណ៍នីត្យានុកូលភាពត្រូវភ្ជាប់ជាមួយប្រភេទទាំងមូលនៃអំពើអមនុស្សធម៌ផ្សេងទៀត និងមិនត្រូវភ្ជាប់តែជាមួយប្រភេទរងនីមួយៗទេ[19]"។ ជំហររបស់អង្គបុរេជំនុំជម្រះ មិនពិចារណាអំពីការទទួលស្គាល់ការពិតដែលថាប្រភេទនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៅចន្លោះយុត្តិសាស្ត្រសង្គ្រាមលោកលើទី II និងពេលបច្ចុប្បន្ននេះបានវិវឌ្ឍន៍ទៅមុខ<u>យ៉ាងសកម្ម</u> ហើយក៏មិនបានគិតពីឥទ្ធិពលបន្តបន្ទាប់ដែលការវិវឌ្ឍន៍នេះមានមក

---

[17] សូមមើលឧទាហរណ៍, ដូចដើងទំព័រខាងលើ កថាខណ្ឌទី៣៧០ ដែលក្នុងកថាខណ្ឌនេះអង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដោសារតែ "ការរំលោភលើផ្លូវភេទជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលចាំបាច់ត្រូវតែមានធាតុផ្សំសំខាន់ៗដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀតដែរ ដូចជាលក្ខខណ្ឌតម្រូវថាអំពើដែលបង្កើតបានជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬដោយមានការរៀបចំ" អង្គបុរេជំនុំជម្រះ មិនអាចរកឃើញថាការរំលោភលើផ្លូវភេទជាទូទៅនៅក្នុងក្រមព្រហ្មទណ្ឌជាតិក្នុងឆ្នាំ ១៩៧៥ដល់ ១៩៧៩ បានគាំទ្រដល់ការសម្រេចដែលថាការរំលោភផ្លូវភេទ"អាចត្រូវបានទាញចេញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិថាជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ តាមសិទ្ធិរបស់ខ្លួនដោយផ្អែកលើគោលការណ៍ទូទៅនៃច្បាប់ដែលបានទទួលស្គាល់ដោយជាតិដែលមានអារ្យធម៌ខ្ពស់"ឡើយ។ មេធាវីការពារក្តីយល់ឃើញថាការធ្វើឲ្យការជម្លៀសប្រជាជនដោយបង្ខំទៅជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺពិតជាមិនបានគាំទ្រការអះអាងថាលក្ខណ:នៃការប្រព្រឹត្តជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិក្នុងឆ្នាំ១៩៧៥ និង១៩៧៩ ស្របទៅនឹងគោលការណ៍នីត្យានុកូលភាពឡើយ ។

[18] ដូចដើងទំព័រខាងលើ, កថាខណ្ឌទី៣៥៥។

[19] ដូចដើងទំព័រខាងលើ, កថាខណ្ឌទី៣៧៨។

00681374



លើប្រភេទនៃ "អំពើអមនុស្សធម៌ដទៃទៀត"ដែរ ។ ការវិវឌ្ឍន៍នេះប៉ះពាល់ដល់ការបកស្រាយថាតើការប្រព្រឹត្តណាមួយមាន "លក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នា" ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូច្នេះហើយវាគឺជាអំពើអមនុស្សធម៌ដទៃទៀត។ សារណាបន្ថែម គឺចាំបាច់ដើម្បីបង្ហាញថា ទោះបីជាមិនមានការចាត់ទុកតាមផ្លូវតុលាការអំពើអមនុស្សធម៌ដទៃទៀតថា ជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ*ខ្លួនឯងផ្ទាល់*[20] ក៏ដោយ ក៏ប្រភេទរងដ៏ទៃទៀតត្រូវតែយកទៅពិចារណាផងដែរ ដោយអនុលោមតាមគោលការណ៍នីត្យានុកូលភាព។

**v. ថាតើគោលការណ៍គ្មានទោសបើគ្មានច្បាប់ចែងត្រូវបានការពារដោយការអនុវត្ត"អំពើអមនុស្សធម៌ដទៃទៀត" ដោយអង្គបុរេជំនុំជម្រះ ដែរ ឬអត់**

១១. អង្គបុរេជំនុំជម្រះយល់ឃើញថាពាក្យថា "ផ្សេងទៀត" ទាញចេញពីគោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយនូវអ្វីដែលមានភាពស្រដៀងគ្នា (*ejusdem generis*) នៃវិធានក្នុងការបកស្រាយ ដែលក្នុងន័យនោះអំពើអមនុស្សធម៌ផ្សេងទៀត អាចត្រឹមតែរួមបញ្ចូលអំពើនានា ដែលមានភាពអមនុស្សធម៌[21]។ ក្នុងបរិបទនៃច្បាប់ Civil Law ដែលនៅជាធរមាននៅ អវតក ដែលចែងថាទោសត្រូវមានចែងជាក់លាក់ដោយច្បាប់ គឺមានភាពមិនស៊ីសង្វាក់ នឹងគោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយនូវអ្វីដែលមានភាពស្រដៀងគ្នា (*ejusdem generis*) សារណាបន្ថែម គឺចាំបាច់ដើម្បីបង្ហាញថា តើហេតុអ្វីបានជាការទាញចេញទាំងស្រុងនៃការបកស្រាយវិធានតាមបែប Common Law រំលោភគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង។

**ឃ. ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ**

**i. ថាតើការទទួលខុសត្រូវរបស់ថ្នាក់លើ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែរឬទេ**

១២. អង្គបុរេជំនុំជម្រះភ័ន្តច្រឡំក្នុងការកំណត់ថាការទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ១៩៧៥ ដល់១៩៧៩[22] ហើយថាទ្រឹស្តីនេះ មិន

---

[20] សូមមើល ដូចជើងទំព័រខាងលើ, ដកស្រង់ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Blagojević & Jokić*, IT-02-60-T, សាលក្រម ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥, កថាខណ្ឌទី៦២៤។

[21] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី៣៨៨។

[22] សូមមើលឧទាហរណ៍, ដូចជើងទំព័រខាងលើ, កថាខណ្ឌទី៤៥៨។

កំណត់តែមេបញ្ហាការឃោធាប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានគ្រប់ដណ្តប់ថ្នាក់លើដែលមិនមែនជាមេបញ្ហាការឃោធាផងដែរ[23]។ អង្គបុរេជំនុំជម្រះផ្អែកលើការបកស្រាយខុសនូវអ្វីដែលគេត្រូវការដើម្បីរកឱ្យឃើញថា ទម្រង់នៃការទទួលខុសត្រូវមួយមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ សារណាន្ថែមគឺចាំបាច់ ដើម្បីបង្កើត និងវិភាគលក្ខខណ្ឌចាំបាច់ដើម្បីរកឱ្យឃើញថាទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ពិតជាមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

**ii.ថាតើបញ្ហាមួយចំនួនដែលបានលើកឡើងដោយមេធាវីការពារក្តីទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាទឡ្ហីករណ៍ផ្នែកយុត្តាធិការដែរ ឬយ៉ាងណា**

១៣. អង្គជំនុំបុរេជំនុំជម្រះមានកំហុសក្នុងការកំណត់ថា ការទទួលការទទួលខុសត្រូវរបស់ថ្នាក់លើអាចអនុវត្តបានតែជម្លោះប្រដាប់អាវុធ មិនមានលក្ខណៈជាបញ្ហាយុត្តាធិការ[24]ទេ ។ សារណាបន្ថែម គឺចាំបាច់ ដើម្បីពន្យល់ថាចំណុនេះគឺជាការប្តឹងជំទាស់បញ្ហាយុត្តាធិការ ព្រោះថាប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទទួលយកការសម្រេចដោយភ័ន្តច្រឡំរបស់អង្គបុរេជំនុំជម្រះ ដែលថាបញ្ហាទាំងនេះមិនមែនទាក់ទងនឹងបញ្ហាយុត្តាធិការ នោះនឹងនាំឱ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលបញ្ហាទាំងនេះថាមិនមែនជាអញ្ញាត្រកម្មសមស្រប[25] ។

អាស្រ័យលើមូលហេតុទាំងអស់ដែលបានលើកឡើងនៅទីនេះ មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាត ទទួលយក និងពិចារណាសារណាបន្ថែមលើបញ្ហាដែលបានលើកឡើង ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

---

[23] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី៤៥៩។

[24] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១០២។

[25] មេធាវីការពារក្តីបានដាក់អញ្ញាត្រកម្មទាំងនេះស្របតាមវិធាន (៨៩) (ក) (យុត្តាធិការរបស់អង្គជំនុំជម្រះ)។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣ ខែ **ឧសភា** ឆ្នាំ **២០១១**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**